កម្មវិធីផ្សាយផ្ទាល់ការបង្រៀនបំប៉ន

LIVE LIVE TEACHING

# វិញ្ញាសាតែងសេចក្ដី
# ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

បង្រៀនដោយ **វ៉ាន់ វី**
ដេប៉ាតឺម៉ង់ភាសាវិទ្យា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## វិញ្ញាសាទី ៩

**ប្រធាន** ៖ អ្នកសិក្សាលើកឡើងថា “រឿងកុលាបប៉ៃលិនបានផ្ដល់នូវគតិអប់រំដ៏មានសារប្រយោជន៍ចំពោះយុវជនខ្មែរ” ។ ចូរបកស្រាយដោយលើកឧទាហរណ៍ពីក្នុងរឿងនេះមកបញ្ជាក់ ។

# គម្រោងតែងទូទៅ

## ១- សេចក្តីផ្តើម

- លំនាំបញ្ហា៖ ផ្តើមពីរឿងកុលាបប៉ៃលិន
- ចំណូលបញ្ហា៖ ដាក់មតិប្រធាន
- ចំណោទបញ្ហា៖ ចោទបែបប្រធានពន្យល់

## ២- តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី + ពន្យល់ពាក្យគន្លឹះ + ពន្យល់ន័យប្រធាន
- បកស្រាយប្រធាន ៖
  - គំនិតសំខាន់ទី ១ ៖ ឱ្យពួកយុវជនចេះតស៊ូក្នុងជីវិត
  - គំនិតសំខាន់ទី ២ ៖ ឱ្យពួកយុវជនកុំរើសអើងការងារ
  - គំនិតសំខាន់ទី ៣ ៖ បណ្តុះគំនិតផ្សះផ្សាវណ្ណៈ
  - គំនិតសំខាន់ទី ៤ ៖ បណ្តុះស្មារតីសាមគ្គី
- សរុប

## ៣- សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន
- មតិផ្ទាល់ខ្លួន

# សេចក្តីអធិប្បាយ

រឿងកុលាបប៉ៃលិន គឺជាប្រលោមលោកទំនើបបែបមនោសញ្ចេតនា និពន្ធឡើងដោយលោក ញ៉ុក ថែម នាសម័យអាណានិគមបារាំង ។ រឿងនេះបានបោះពុម្ពផ្សាយលើកដំបូងនៅឆ្នាំ ១៩៤៣ និងបានបញ្ចូលក្នុងកម្មវិធីសិក្សាជាតិនៅឆ្នាំ ១៩៥៨ ។ វណ្ណកម្មមួយនេះមានប្រជាប្រិយភាពពុំចាញ់រឿងផ្កាស្រពោនរបស់អ្នកនិពន្ធ នូ ហាច ឡើយ ព្រោះបានបង្កប់នូវតម្លៃអប់រំល្អៗជាច្រើន ដោយបានលើកយកដំណើរជីវិតតស៊ូរបស់តួអង្គចៅចិត្រមករៀបរាប់ ចាប់តាំងពីចៅចិត្រក្លាយខ្លួនជាក្មេងកំព្រា ទៅធ្វើការជាកម្មករត្បូងនៅប៉ៃលិន រហូតដល់បានក្លាយជាកូនប្រសាររបស់ចៅកែត្បូង គឺហ្លួងរតនសម្បត្តិនៅទីបញ្ចប់ ។ អាស្រ័យហេតុនេះ ទើបក្រោយពីបានសក្សារឿងនេះហើយ អ្នកសិក្សាបានលើកឡើងថា "រឿងកុលាបប៉ៃលិនបានផ្តល់នូវគតិអប់រំដ៏មានសារប្រយោជន៍ចំពោះយុវជនខ្មែរ"។

តើរឿងនេះបានផ្តល់គតិអប់រំសំខាន់ៗអ្វីខ្លះដល់យុវជនខ្មែរ?

ដើម្បីបានជាជំនួយដល់ការបកស្រាយមតិប្រធានខាងលើនេះ យើងគប្បីយល់ន័យនៃពាក្យគន្លឹះមួយចំនួនជាមុនសិន ។ ពាក្យ "គតិអប់រំ" ក្នុងទីនេះបានសេចក្តីថា គំនិតឬបញ្ញាញាណសម្រាប់ការណែនាំ ទូន្មាន ប្រៀនប្រដៅឱ្យល្អ ។ ចំណែកពាក្យ "សារប្រយោជន៍" មានន័យថា ប្រយោជន៍យ៉ាងសំខាន់ ប្រយោជន៍ដ៏មានខ្លឹមសារ។ ឯពាក្យ "យុវជន" សំដៅដល់ជនកំលោះក្រមុំ ជនធំពេញវ័យ ជាពលរដ្ឋពេញកម្លាំងសម្រាប់ជួយជាតិ ។ ដូចនេះ គំនិតប្រធានខាងលើចង់បានន័យថា រឿងកុលាបប៉ៃលិនជារឿងមួយដែលបានផ្តល់នូវគំនិតឬប្រាជ្ញាញាណសម្រាប់ជាការណែនាំ ទូន្មាន ប្រៀនប្រដៅ ដែលប្រយោជន៍យ៉ាងសំខាន់ចំពោះជនកំលោះក្រមុំ ឬជនធំពេញវ័យរបស់ខ្មែរពោលគឺពលរដ្ឋពេញកម្លាំងរបស់ជាតិខ្មែរ ។

ជាការពិត ប្រលោមលោករឿងកុលាបប៉ៃលិនរបស់លោក ញ៉ុក ថែម បានបង្កប់នូវឧត្តមគតិល្អៗដ៏មានប្រយោជន៍ជាច្រើនចំពោះប្រជាជនខ្មែរជាទូទៅ ពិសេសគឺយុវជន ដែលជាសសរទ្រូងនៃប្រទេសជាតិនេះតែម្តង ។ គំនិតអប់រំសំខាន់ចម្បងក្នុងវណ្ណកម្មមួយនេះ គឺចង់បង្ហាញឱ្យយុវជនខ្មែរចេះតស៊ូក្នុងជីវិត ឱ្យចេះតស៊ូចំពោះការងារ ឱ្យចេះសង្ឃឹមលើកម្លាំងផ្ទាល់ខ្លួនជាជាងពឹងផ្អែកលើព្រេងវាសនា ។ តាមសាច់រឿង ក្រោយពីតាចឹមជាឪពុកបានទទួលមរណភាពទៅ ថៅចិត្រត្រូវរស់នៅកំព្រីកំព្រាគ្មានទីពឹង ប៉ុន្តែពុំមានអស់សង្ឃឹមក្នុងជីវិតឡើយ ។ យើងឃើញថា ថៅចិត្រតែងតែយកបណ្តាំឪពុកៈ “អត្តាហិ អត្តនោ នាថោ” មកគិតនិងប្រតិបត្តិតាមជានិច្ច ពោលគឺត្រូវរស់នៅដោយពឹងផ្អែកលើសមត្ថភាពខ្លួនឯងជាធំ ។ ថៅចិត្រខិតខំធ្វើការខាងជីកត្បូង ដែលជាការងារធ្ងន់ ជាការងារថៅចិត្រពុំធ្លាប់ធ្វើសោះ តែយុវជននេះពុំរាថយនឹងការងារឡើយ ។ ហេតុនេះទើបពួកកម្មករត្បូងដទៃទៀតពុំបានមើលស្រាលថៅចិត្រឡើយ ផ្ទុយទៅវិញគេបានរាប់អាននិងឱ្យតម្លៃលើសមត្ថភាពរបស់ថៅចិត្រ ។ ទន្ទឹមគ្នានេះដែរ ក៏ដោយសារសេចក្តីតស៊ូនេះហើយ ទើបធ្វើឱ្យលោកហ្លួងរតនសម្បត្តិពេញចិត្តពេញថ្លើមថៅចិត្រ រហូតប្រគល់ការងារកាន់បញ្ជីដល់ថៅចិត្រទៀតផង។

ម្យ៉ាងទៀត រឿងនេះក៏បានដឹកនាំឱ្យយុវជនកុំឱ្យប្រកាន់អាកប្បកិរិយាតឹងតែងពេកក្នុងការជ្រើសរើសការងារ គឺបើដល់ពេលទាល់ហើយ ទោះការងារពិបាកឬស្រួល ផ្តល់កម្រៃច្រើនឬតិច ក៏គួរតែប្រកបសិនដែរ ឱ្យតែជាការងារសុចរិត ។ ជាតួយ៉ាង ថៅចិត្រពុំបានរើសអើងថា ការងារនេះថោកទាប ឬការងារនោះថ្លៃថ្នូរឡើយ ។ ពិតមែនតែថៅចិត្រមានប្រកាសនីយបត្រ ដែលបញ្ជាក់ថាគេមានចំណេះវិជ្ជាកម្រិតវប្បធម៌ទូទៅយ៉ាងបង្គួរ ប៉ុន្តែថៅចិត្របានសម្រេចចិត្តធ្វើជាកម្មករជីកត្បូងនៅផ្ទះលោកហ្លួងរតនសម្បត្តិ ដោយមិនគិតថា ជាការងារតូចតាចឡើយ ។ ត្រង់នេះមានសម្តីថៅចិត្រតបទៅហ្លួងរតនសម្បត្តិយ៉ាងម៉ឺងម៉ាត់ដូច្នេះ “មនុស្សដទៃទៀត គេទ្រាំធ្វើបានយ៉ាង

ណា ឯខ្ញុំបាទគង់ធ្វើបានដូចជាគេដែរ សូមព្រះតេជព្រះគុណកុំព្រួយឱ្យសោះ” ។ លុះតមក ក្នុងឋានៈជាកម្មករជីកត្បូងម្នាក់ម្នាក់ ចៅចិត្របានយកចិត្តទុកដាក់បំពេញភារកិច្ចខ្លួនបានល្អ ដោយមិនទាមទារការឈប់សម្រាកថ្ងៃសៅរ៍-អាទិត្យឡើយ ។ ទោះបីការងារនោះលំបាកធ្ងន់ធ្ងរ ប្រឡាក់ភក់ ហាលថ្ងៃ ហាលភ្លៀង ហាលខ្យល់ក៏ដោយ ក៏ចៅចិត្រនៅតែតស៊ូ ព្យាយាមដូចពាក្យនិយាយរ៉ាប់រងមកពីមុននេះមែន ។

មិនត្រឹមតែប៉ុណ្ណោះ អ្នកនិពន្ធ ញ៉ុក ថែម បានបណ្តុះគំនិតផ្សះផ្សាវណ្ណៈពីរ ដែលនៅដាច់គ្នាដូចមេឃនិងដី ពោលគឺវណ្ណៈអ្នកមានតំណាងដោយលោកហ្លួងរតនសម្បត្តិ និងនាងយុននារី និងវណ្ណៈអ្នកក្រតំណាងដោយចៅចិត្រ ។ លោកចង់អប់រំឱ្យវណ្ណៈអ្នកមានលះបង់ចិត្តគំនិតប្រកាន់មានក្រ ហើយអ្នកមានឋានៈតូចទាបក៏គប្បីចេះជួយយកអាសាវណ្ណៈខ្ពស់ ទើបសង្គមរស់នៅបានសុខដុមរមនា ។ ជាក់ស្តែង សាច់រឿងនេះបានបង្ហាញថា នៅពេលជួបនឹងចៅចិត្រដំបូង យុននារី កូនស្រីបណ្តូលចិត្តរបស់ហ្លួងរតនសម្បត្តិ បានសំឡឹងមើលកម្មករថ្មីនេះតាំងអំពីក្បាលរហូតដល់ចុងជើង ក៏លាន់មាត់ថា **“កម្មករនេះស្គមដូចជាអ្នកញៀនអាភៀន នឹងមានកម្លាំងជីកដីបានឬប៉ា? កូនយល់ថាតម្រូវឱ្យធ្វើការលាងចានក្នុងផ្ទះបាយវិញជាជាង ?”** ។ ប៉ុន្តែ ពេលវេលាកន្លងទៅ នាងបានកែប្រែទស្សនៈរបស់នាងចំពោះចៅចិត្រ រហូតព្រមទទួលយកក្តីស្រឡាញ់របស់ចៅចិត្រទៀត ។ ចំណែកលោកហ្លួងរតនសម្បត្តិក៏ពុំប្រកាន់ថា ចៅចិត្រជាអ្នកមានឬក្រដែរ រហូតព្រមលើកនាងយុននារីឱ្យជាភរិយារបស់យុវជននេះទៀត ដ្បិតបានមើលឃើញពីគុណសម្បត្តិច្រើនប្រការ ពិសេសគឺតម្រិះវិជ្ជា ចរិត្តស្លូតបូត ភាពស្មោះត្រង់ និងការលះបង់របស់ចៅចិត្រចំពោះគ្រួសាររបស់លោក ។

ក្រៅពីគំនិតអប់រំខាងលើ រឿងកុលាបប៉ៃលិនក៏បានបង្ហាញយុវជនខ្មែរឱ្យស្គាល់នូវកម្លាំងសាមគ្គីធម៌ ។ ភាពសមគ្គីជាធ្លុងមួយតែងនាំមកនូវជោគជ័យផងនានា ។

តាមដំណើររឿង ថៅចិត្រនិងក្រុមកម្មករត្បូងមានសាមគ្គីភាពនឹងគ្នាណាស់ គឺមិនប្រកាន់ថាអ្នកណាចូលធ្វើការមុន ឬធ្វើការក្រោយនោះទេ ។ បើមានកិច្ចអ្វី គេតែងជួយរំលែកការងារគ្នា ។ ឧទាហរណ៍ ពេលតាស៊ុន អ្នកបើកឡានរបស់លោកហ្លួងរតនសម្បត្តិជាប់រវល់ ថៅចិត្រក៏ជួយជំនួសដៃជើងគាត់ ដោយជួយបើកឡានជូនថៅកែទៅក្រុងបាត់ដំបង ។ នៅពេលមានអាសន្នត្រូវចោរប្លន់នៅពាក់កណ្ដាលព្រៃក្ដី និងចោរប្លន់នៅផ្ទះលោកហ្លួងរតនសម្បត្តិក្ដី ថៅចិត្រព្រមដោយក្រុមកម្មករត្បូងទាំងអស់ បានសហការគ្នាកម្ចាត់ក្រុមចោរប្លន់រហូតបានជោគជ័យ ដោយម្នាក់ៗហ៊ានយកអាយុជីវិតរបស់ខ្លួនទៅប្ដូរ ដើម្បីការពារអាយុជីវិតនិងទ្រព្យសម្បត្តិរបស់ថៅហ្វានាយខ្លួន។ នេះហើយគឺស្មារតីសាមគ្គីភាពរបស់ក្រុមកម្មករ ។

រួមសេចក្ដីមក វណ្ណកម្មរឿងកុលាបប៉ៃលិន ពុំមែនរួមចំណែកត្រឹមតែជាការកម្សាន្តដល់អ្នកអានប៉ុណ្ណោះទេ ថែមទាំងបានបង្កប់នូវគតិអប់រំជាប្រយោជន៍ដ៏សំខាន់ចំពោះយុវជនខ្មែរទៀតផង ។ ប្រយោជន៍ដ៏មានខ្លឹមសារនៃរឿងនេះ គឺជួយផ្សះផ្សាវណ្ណៈអ្នកមាននិងអ្នកក្រ, ឱ្យយុវជនចេះតស៊ូពឹងលើកម្លាំងខ្លួនឯង, ឱ្យយុវជនកុំរើសអើងការងារសុចរិត និងឱ្យយុវជនចេះសាមគ្គីគ្នា។

ឆ្លងតាមការបកស្រាយនៅខាងលើរួចមក យើងអាចវាយតម្លៃជាចុងក្រោយថា មតិរបស់ប្រធានពិតជាមានតម្លៃដ៏ប្រពៃ ព្រោះបានអប់រំឱ្យយុវជនខ្មែរលះបង់គំនិតប្រកាន់វណ្ណៈ ចេះតស៊ូក្នុងជីវិត និងចេះសាមគ្គីគ្នាជាដើម ។ ម្ល៉ោះហើយ យើងជាយុវជនជំនាន់ក្រោយ គប្បីខិតខំសិក្សាស្នាដៃអក្សរសិល្ប៍ខ្មែរ ដោយចេះច្បិចយកគតិទូន្មានល្អៗ សម្រាប់យកដឹកនាំមាគ៌ាជីវិត និងសម្រាប់ជាមូលដ្ឋានខ្លះៗក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យរីកចម្រើន ។

# ឯកសារពិគ្រោះ


កាន់ ចាន់ដារ៉ា និង វ៉ាន់ វី ***តែងសេចក្ដី៖ ប្រធានពន្យល់*** ភ្នំពេញ ឆ្នាំ២០១២។

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ***វិធីសាស្ត្រនៃការសរសេរតែងសេចក្ដី*** *(សម្រាប់មធ្យមសិក្សាទុតិយភូមិ)* ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៧។

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ***វិធីសាស្ត្រនៃការសរសេរតែងសេចក្ដី*** *(សម្រាប់មធ្យមសិក្សាបឋមភូមិ)* ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៨។

សែម សូរ, ថោង ផែល និងអ្នកដទៃទៀត ***វិញ្ញាសាតែងសេចក្ដីគំរូ*** បណ្ណាគារមាយើង ឆ្នាំ១៩៧១។